**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តកណ្តាល**

សំណុំរឿងរដ្ឋប្បវេណីលេខ៖១២៩៨
ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០២៣
សាលក្រមលេខ ០៤២/ឋ
ចុះថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០២៤

# ក្នុងនាមប្រជារាស្ត្រខ្មែរ
# សាលាដំបូងខេត្តកណ្តាល

បានបញ្ចប់នីតិវិធីទាញហេតុផលដោយផ្ទាល់មាត់នៅថ្ងៃទី១០ ខែមេសា ឆ្នាំ២០២៤
និងប្រកាសជាសាធារណៈនៅថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០២៤
លើសំណុំរឿងរដ្ឋប្បវេណីលេខ ១២៩៨ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០២៣

**ដោយមានសមាសភាព**

**ចៅក្រមជំនុំជម្រះ**

លោក [redacted] ចៅក្រមនៃសាលាដំបូងខេត្តកណ្តាល

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ក្រឡាបញ្ជីនៃសាលាដំបូងខេត្តកណ្តាល

**រវាងដើមចោទ**

ឈ្មោះ [redacted] សុខន ភេទប្រុស កើតឆ្នាំ១៩៦២ ជនជាតិខ្មែរ សញ្ជាតិខ្មែរ មានអាស័យដ្ឋាន [redacted]

-ដែលមានលោកមេធាវី [redacted] ជាអ្នកតំណាងដោយអាណត្តិឲ្យដើមចោទ។

**និងសហចុងចម្លើយ ៖**

១.ឈ្មោះ [redacted] វុទ្ធី ភេទប្រុស កើតឆ្នាំ១៩៦០ សញ្ជាតិខ្មែរ កាន់អត្តសញ្ញាប័ណ្ណសញ្ជាតិខ្មែរលេខ ០២០៥២៥០០៤(០១) ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៥ និងឈ្មោះ [redacted] សំអាត ភេទស្រី កើតឆ្នាំ១៩៦៣ សញ្ជាតិខ្មែរ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ០២០០១៨៥៨៩(០១) ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៥ (ត្រូវជាប្រពន្ធ) មានអាស័យដ្ឋានផ្ទះលេខ [redacted]។

២.ឈ្មោះ [redacted] ប៊ុនថេត ភេទប្រុស កើតឆ្នាំ១៩៨៨ សញ្ជាតិខ្មែរ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ ០២១៣១៥៧៨៧ ចុះថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០២០ និងឈ្មោះ [redacted] កាស់ ភេទស្រី កើតឆ្នាំ១៩៨៨ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ០២០៦២៤៧២០(០១) ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១៦ (ត្រូវជាប្រពន្ធ) មានអាស័យដ្ឋានផ្ទះ [redacted]។

## អង្គហេតុ និងការអះអាងរបស់គូភាគី

### ក. ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឲ្យតុលាការចេញ៖

១.បង្គាប់ឲ្យសហចុងចម្លើយរួមគ្នាសងប្រាក់ដើមនៅជំពាក់សរុបចំនួន ៦៥.០០០(ប្រាំមួយម៉ឺនប្រាំពាន់) ដុល្លារអាមេរិក ទៅឲ្យដើមចោទ។

២.បង្គាប់ឲ្យសហចុងចម្លើយរួមគ្នាសងការប្រាក់ក្នុងអត្រា ១.៥% ក្នុងមួយខែ លើប្រាក់ដើមនៅជំពាក់ចំនួន ៦៥.០០០(ប្រាំមួយម៉ឺនប្រាំពាន់) ដុល្លារអាមេរិក ដោយគិតចាប់ពីថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២២ រហូតដល់ថ្ងៃសងរួចជាក់ស្តែង។

៣.បង្គាប់ឲ្យសហចុងចម្លើយរួមគ្នាសងប្រាក់ពិន័យក្នុងអត្រា ៥% ក្នុងមួយខែ លើប្រាក់ដើមនៅជំពាក់ចំនួន ៦៥.០០០(ប្រាំមួយម៉ឺនប្រាំពាន់) ដុល្លារអាមេរិក ដោយគិតចាប់ពីថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២២ រហូតដល់ថ្ងៃសងរួចជាក់ជាក់ស្តែង។

៤.បង្គាប់ឲ្យសហចុងចម្លើយរួមគ្នាសងសំណងជំងឺចិត្ត ការខូចខាតបង់ពេលវេលា និងប្រាក់កម្រៃសេវាមេធាវីចំនួន ២០.០០០(ពីរម៉ឺន)ដុល្លារអាមេរិក ទៅឲ្យដើមចោទ។

៥.សាលក្រមនេះមានអានុភាពអាចអនុវត្តជាបណ្តោះអាសន្ន។

៦.ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់សហចុងចម្លើយ។

## ខ. អង្គហេតុ និងចំណុចវិវាទ

### ខ.១. ការសង្ខេបគ្រួសៗអំពីរឿងក្តី

កាលពីថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២២ សហចុងចម្លើយមានចំនួន ០៤(បួន)នាក់ មានឈ្មោះដូចតទៅ ១.ឈ្មោះ [redacted] ប៊ុនថេត, ២.ឈ្មោះ [redacted] កាស់, ៣.ឈ្មោះ [redacted] សំអាត និង៤.ឈ្មោះ [redacted] វុទ្ធី បានខ្ចីប្រាក់ពីដើមចោទឈ្មោះ [redacted] សុខន ចំនួន ១០០.០០០(ដប់ម៉ឺន)ដុល្លារអាមេរិក ផ្អែកតាមកិច្ចសន្យាខ្ចីបរិភោគ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២២។ តាមកិច្ចសន្យានេះខ្ចីរយៈពេល ០៣(បី)ខែ គិតចាប់ពីថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២២ រហូតដល់ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២២ អត្រាការប្រាក់តាមការព្រមព្រៀងគ្នា ២%(ពីរ)ភាគរយ ក្នុងមួយខែអត្រាពិន័យ ៥%(ប្រាំ)ភាគរយ ក្នុងមួយខែ របៀបសង សងការប្រាក់រាល់ខែ និងប្រាក់ដើមនៅកាលបរិច្ឆេទសងចុងក្រោយ។ នៅពេលដល់កាលកំណត់សងចុងក្រោយសហចុងចម្លើយមិនបានសងប្រាក់ដើមផ្តាច់តាមកិច្ចសន្យាឡើយ ពោលសងបានតែ ៤០.០០០(បួនម៉ឺន)ដុល្លារអាមេរិកទៀត ដោយនៅជំពាក់ ៦០.០០០(ប្រាំមួយម៉ឺន)ដុល្លារអាមេរិក ដែលនៅមិនទាន់បានសងទៅឲ្យដើមចោទ។ បន្ទាប់មកនៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២២ សហចុងចម្លើយបានស្នើសុំដើមចោទខ្ចីបន្តលើប្រាក់ដើមចំនួន ៦០.០០០(ប្រាំមួយម៉ឺន)ដុល្លារអាមេរិក សម្រាប់រយៈពេលបន្តចំនួន ០៥(ប្រាំ)ខែទៀត ដោយគិតចាប់ពីថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២២ រហូតដល់ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២២។ ទន្ទឹមនេះសហចុងចម្លើយក៏បានសុំខ្ចីបន្ថែមចំនួន ៥.០០០(ប្រាំពាន់)ដុល្លារអាមេរិកទៀត ដោយសហចុងចម្លើយ និងដើមចោទបានឯកភាពគ្នាប្រាប់បញ្ចូលគ្នានូវបំណុលដែលនៅជំពាក់បូកនឹងបំណុលដែលខ្ចីបរិភោគបន្ត ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២២។ តាមលក្ខខណ្ឌនៃកិច្ចសន្យាខ្ចីបរិភោគបន្តនេះបានឯកភាពគ្នាតាមលក្ខខណ្ឌ៖ រយៈពេលខ្ចីបន្តចំនួន ០៥(ប្រាំ)ខែ ដោយគិតចាប់ពីថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២២ រហូតដល់ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២២ អត្រាការប្រាក់តាមការព្រមព្រៀងគ្នា ២%(ពីរ)ភាគរយ ក្នុងមួយខែ អត្រាពិន័យ ៥%(ប្រាំ)ភាគរយ ក្នុងមួយខែ (ពិន័យក្នុងករណីបំពានលក្ខខណ្ឌនៃការសងប្រាក់)របៀបសង សងការប្រាក់រាល់ខែ និងប្រាក់ដើមនៅកាលបរិច្ឆេទកំណត់សងចុងក្រោយ ហើយជាការធានាអះអាងទូទាត់សងប្រាក់ដើមផ្តាច់សងសហចុងចម្លើយបានស្នើសុំប្រគល់មូលប្បទានប័ត្រធនាគារABA ចំនួន ០១(មួយ)សន្លឹក លេខ១៩០៥៥៤ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២២ បញ្ជាក់ទឹកប្រាក់ចំនួន ៦៥.០០០(ប្រាំមួយម៉ឺនប្រាំពាន់)ដុល្លារអាមេរិក ដើម្បីធានាប្រាក់កម្ចីតាមកិច្ចសន្យាខ្ចីបរិភោគបន្ត ចុះថ្ងៃទី៣០ ខែមិថុនា មានទីតាំងស្ថិតនៅភូមិកំពង់សំណាញ់១ សង្កាត់កំពង់សំណាញ់ ក្រុងតាខ្មៅ ខេត្តកណ្តាល មានបណ្ណបញ្ជាក់ប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ០៨១១០៦០៤-១៥២១ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០២០ ចេញ



Scanned with CamScanner

ដោយមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តកណ្ដាល។ បន្ទាប់ពីចុះកិច្ចសន្យាខ្ចីបរិភោគបន្ត ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២២ រួចហើយ សហចុងចម្លើយបានបំពានកាតព្វកិច្ចតាមកិច្ចសន្យា ដោយមិនបាន សងការប្រាក់ និងប្រាក់ដើមទាល់តែសោះ សូម្បីតែមូលប្បទានប័ត្រធនាគារដែលបានប្រគល់ឲ្យសម្រាប់ទូទាត់សង លើប្រាក់ដើម ពេលយកទៅដកប្រាក់នៅធនាគារ ក៏មិនអាចប្រតិបត្តិការសាច់ប្រាក់បានដែរ។ បច្ចុប្បន្នសហចុង ចម្លើយនៅជំពាក់ប្រាក់ដើមចំនួន ៦៥.០០០(ប្រាំមួយម៉ឺនប្រាំពាន់)ដុល្លារអាមេរិកដដែលរួមទាំងការប្រាក់ និងប្រាក់ ពិន័យតាមកិច្ចសន្យា។

**ខ.២.រឿងក្ដីនេះមេធាវីតំណាងដោយអាណត្តិឲ្យដើមចោទថ្លែងការណ៍អំពីការទាមទារមានដូចតទៅ៖**

ដើមចោទឈ្មោះ [redacted] សុខន ដោយមានលោកមេធាវី [redacted] ជាអ្នក តំណាងដោយអាណត្តិឲ្យដើមចោទបានធ្វើសេចក្ដីថ្លែងការណ៍ថា៖ "នាងខ្ញុំសុំរក្សាខ្លឹមសារនៃការទាមទារទាំង ៦ចំណុច ដូចមានក្នុងពាក្យបណ្ដឹងចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០២៣ ទុកជាបានការដដែល ដោយស្នើសុំតុលាការចេញសាលក្រម៖

១.បង្គាប់ឲ្យសហចុងចម្លើយរួមគ្នាសងប្រាក់ដើមនៅជំពាក់សរុបចំនួន ៦៥.០០០(ប្រាំមួយម៉ឺនប្រាំពាន់) ដុល្លារអាមេរិក ទៅឲ្យដើមចោទ។

២.បង្គាប់ឲ្យសហចុងចម្លើយរួមគ្នាសងការប្រាក់ក្នុងអត្រា ១.៥% ក្នុងមួយខែ លើប្រាក់ដើមនៅជំពាក់ចំនួន ៦៥.០០០(ប្រាំមួយម៉ឺនប្រាំពាន់) ដុល្លារអាមេរិក ដោយគិតចាប់ពីថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២២ រហូតដល់ថ្ងៃ សងរួចជាក់ស្ដែង។

៣.បង្គាប់ឲ្យសហចុងចម្លើយរួមគ្នាសងប្រាក់ពិន័យក្នុងអត្រា ៥% ក្នុងមួយខែ លើប្រាក់ដើមនៅជំពាក់ចំនួន ៦៥.០០០(ប្រាំមួយម៉ឺនប្រាំពាន់) ដុល្លារអាមេរិក ដោយគិតចាប់ពីថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២២ រហូតដល់ថ្ងៃ សងរួចជាក់ជាក់ស្ដែង។

៤.បង្គាប់ឲ្យសហចុងចម្លើយរួមគ្នាសងសំណងជំងឺចិត្ត ការខូចខាតបង់ពេលវេលា និងប្រាក់កម្រៃសេវា មេធាវីចំនួន ២០.០០០(ពីរម៉ឺន)ដុល្លារអាមេរិក ទៅឲ្យដើមចោទ។

៥.សាលក្រមនេះមានអានុភាពអាចអនុវត្តជាបណ្ដោះអាសន្ន។

៦.ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់សហចុងចម្លើយ។

**ដោយសូមអះអាងអំពីអង្គហេតុចាំបាច់ ដើម្បីបញ្ជាក់ការទាមទារ និងអង្គហេតុដែលជា មូលហេតុនៃការ ទាមទារដូចតទៅ៖**

កាលពីថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២២ សហចុងចម្លើយមានចំនួន ០៤(បួន)នាក់ មានឈ្មោះដូចតទៅ ១.ឈ្មោះ [redacted] ប៊ុនថេត, ២.ឈ្មោះ [redacted] កាស់, ៣.ឈ្មោះ [redacted] សំអាត និង៤.ឈ្មោះ [redacted] វុទ្ធី បានខ្ចីប្រាក់ពីដើមចោទ ឈ្មោះ [redacted] សុខន ចំនួន ១០០.០០០(ដប់ម៉ឺន)ដុល្លារអាមេរិក ផ្អែកតាមកិច្ចសន្យាខ្ចីបរិភោគ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២២។ តាមកិច្ចសន្យានេះខ្ចីរយៈពេល ០៣(បី)ខែ គិតចាប់ពីថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២២ រហូតដល់ថ្ងៃ ទី៣០ ខែមិថុនា ឆ្នាំ២០២២ អត្រាការប្រាក់តាមការព្រមព្រៀងគ្នា ២%(ពីរ)ភាគរយ ក្នុងមួយខែអត្រាពិន័យ ៥% (ប្រាំ)ភាគរយ ក្នុងមួយខែ របៀបសង សងការប្រាក់រាល់ខែ និងប្រាក់ដើមនៅកាលបរិច្ឆេទសងចុងក្រោយ។ នៅ ពេលដល់កាលកំណត់សងចុងក្រោយសហចុងចម្លើយមិនបានសងប្រាក់ដើមផ្ដាច់តាមកិច្ចសន្យាឡើយ ពោលសង បានតែ ៤០.០០០(បួនម៉ឺន)ដុល្លារអាមេរិកទៀត ដោយនៅជំពាក់ ៦០.០០០(ប្រាំមួយម៉ឺន)ដុល្លារអាមេរិក ដែល នៅមិនទាន់បានសងទៅឲ្យដើមចោទ។ បន្ទាប់មកនៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២២ សហចុងចម្លើយបានស្នើសុំ ដើមចោទខ្ចីបន្តលើប្រាក់ដើមចំនួន ៦០.០០០(ប្រាំមួយម៉ឺន)ដុល្លារអាមេរិក សម្រាប់រយៈពេលបន្តចំនួន ០៥(ប្រាំ)



Scanned with CamScanner

ខែទៀត ដោយគិតចាប់ពីថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២២ រហូតដល់ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២២។ ទន្ទឹមនេះ សហចុងចម្លើយក៏បានសុំខ្ចីបន្ថែមចំនួន ៥.០០០(ប្រាំពាន់)ដុល្លារអាមេរិកទៀត ដោយសហចុងចម្លើយ និងដើមចោទបានឯកភាពគ្នាប្រចាំបញ្ចូលគ្នានូវបំណុលដែលនៅជំពាក់បូកនឹងបំណុលដែលខ្ចីបរិភោគបន្ត ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២២។ តាមលក្ខខណ្ឌនៃកិច្ចសន្យាខ្ចីបរិភោគបន្តនេះបានឯកភាពគ្នាតាមលក្ខខណ្ឌ៖ រយៈពេលខ្ចីបន្តចំនួន ០៥(ប្រាំ)ខែ ដោយគិតចាប់ពីថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២២ រហូតដល់ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២២ អត្រាការប្រាក់តាមការព្រមព្រៀងគ្នា ២%(ពីរ)ភាគរយ ក្នុងមួយខែ អត្រាពិន័យ ៥%(ប្រាំ)ភាគរយ ក្នុងមួយខែ (ពិន័យក្នុងករណីបំពានលក្ខខណ្ឌនៃការសងប្រាក់)របៀបសង សងការប្រាក់រាល់ខែ និងប្រាក់ដើមនៅកាលបរិច្ឆេទកំណត់សងចុងក្រោយ ហើយជាការធានាអះអាងទូទាត់សងប្រាក់ដើមផ្តាច់សងសហចុងចម្លើយបានស្នើសុំប្រគល់មូលប្បទានប័ត្រធនាគារABA ចំនួន ០១(មួយ)សន្លឹក លេខ១៩០៥៥៤ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២២ បញ្ជាក់ទឹកប្រាក់ចំនួន ៦៥.០០០(ប្រាំមួយម៉ឺនប្រាំពាន់)ដុល្លារអាមេរិក ដើម្បីធានាប្រាក់កម្ចីតាមកិច្ចសន្យាខ្ចីបរិភោគបន្ត ចុះថ្ងៃទី៣០ ខែមិថុនា មានទីតាំងស្ថិតនៅភូមិកំពង់សំណាញ់១ សង្កាត់កំពង់សំណាញ់ ក្រុងតាខ្មៅ ខេត្តកណ្តាល មានបណ្ណបរិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ០៨១១០៦០៤-១៥២១ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០២០ ចេញដោយមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តកណ្តាល។ បន្ទាប់ពីចុះកិច្ចសន្យាខ្ចីបរិភោគបន្ត ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២២ រួចហើយ សហចុងចម្លើយបានបំពានកាតព្វកិច្ចតាមកិច្ចសន្យា ដោយមិនបានសងការប្រាក់ និងប្រាក់ដើមទាល់តែសោះ សូម្បីតែមូលប្បទានប័ត្រធនាគារដែលបានប្រគល់ឲ្យសម្រាប់ទូទាត់សងលើប្រាក់ដើម ពេលយកទៅដកប្រាក់នៅធនាគារ ក៏មិនអាចប្រតិបត្តិការសាច់ប្រាក់បានដែរ។ បច្ចុប្បន្នសហចុងចម្លើយនៅជំពាក់ប្រាក់ដើមចំនួន ៦៥.០០០(ប្រាំមួយម៉ឺនប្រាំពាន់)ដុល្លារអាមេរិកដដែលរួមទាំងការប្រាក់ និងប្រាក់ពិន័យតាមកិច្ចសន្យា។

ក្នុងករណីដែលបានរៀបរាប់ខាងលើនេះ កូនក្តីយើងខ្ញុំបានភ្ជាប់នូវភស្តុតាងដើម្បីបញ្ជាក់ការទាមទារដូចខាងក្រោម៖

- ឯកសារថតចម្លង នៃកិច្ចសន្យាខ្ចីបរិភោគ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២២។
- ឯកសារថតចម្លង នៃលិខិតប្រគល់ទទួលប្រាក់ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២២។
- ឯកសារថតចម្លង នៃវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលវត្ថុលេខ០៨១១០៦០៤-១៥២១ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០២០ ចេញដោយមន្ទីររៀបចំដែនដីនគរូបនីយកម្ម សំណង់ និងសុរិយោដី។
- ឯកសារថតចម្លង នៃកិច្ចសន្យាខ្ចីបរិភោគបន្តចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២២។
- ឯកសារថតចម្លង នៃលិខិតប្រគល់ទទួលប្រាក់ ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២២។
- ឯកសារថតចម្លង នៃលិខិតប្រគល់ទទួលមូលប្បទានប័ត្រ ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២២។
- ឯកសារថតចម្លង នៃហាងបញ្ជីត្រាស់មី កាលវិភាគសងប្រាក់ ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២២។
- ឯកសារថតចម្លង នៃមូលប្បទានប័ត្រធនាគារABA លេខ១៩០៥៥៤ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២២។

ដើម្បីការពារផលប្រយោជន៍ស្របច្បាប់របស់កូនក្តីយើងខ្ញុំ និងក្នុងគោលបំណងអនុវត្តឱ្យបានត្រឹមត្រូវតាមច្បាប់ផង កូនក្តីយើងខ្ញុំសូមសំណូមពរ **លោកចៅក្រម** មេត្តាសម្រេចសេចក្តីតាមខ្លឹមសារនៃសាលក្រមដែលកូនក្តីខ្ញុំទាមទារឲ្យតុលាការចេញ ដូចបានចែងក្នុងចំណុចទី១ ខាងលើស្របតាមនីតិវិធីច្បាប់។"

ខ.៣.រឿងក្តីនេះសហចុងចម្លើយឈ្មោះ [redacted] វុទ្ធី និងឈ្មោះ [redacted] សំអាត បានធ្វើសេចក្តីថ្លែងការណ៍ថា៖ "យើងខ្ញុំសុំបដិសេធមិនទទួលស្គាល់ការទាមទាររបស់ដើមចោទទាំង ០៦(ប្រាំមួយ) ចំណុចនេះទេ យើងខ្ញុំទាំងពីរនាក់



Scanned with CamScanner

សុំបញ្ជាក់ថា ចំពោះកិច្ចសន្យាខ្ចីប្រាក់លើកទី១ និងលើកទី២ គឺយើងខ្ញុំពិតជាបានផ្តិតមេដៃ នៅលើកិច្ចសន្យាខ្ចីបរិភោគនោះមែន ប៉ុន្តែចំពោះប្រាក់វិញ យើងខ្ញុំពុំបានទទួលសោះឡើយ គឺកូនខ្ញុំឈ្មោះ [redacted]ប៊ុនថេត និងឈ្មោះ [redacted]ភាស់ ពីរនាក់ប្តីប្រពន្ធជាអ្នកទទួលយកទាំងអស់ ចំពោះវិញ្ញាបនប័ត្រសំគាល់អចលនវត្ថុលេខ០៨១១០៦០៤-១៥១២ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០២០ ជាកម្មសិទ្ធិរបស់យើងខ្ញុំ គឺឈ្មោះ [redacted]ប៊ុនថេត និងឈ្មោះ [redacted]ភាស់ ជាអ្នកខ្ចីយកទៅដាក់បញ្ចាំហើយវាប្រាប់យើងខ្ញុំថាសុំខ្ចីតែរយៈពេល ០៣ខែទេ វានឹងលស់មកឲ្យខ្ញុំវិញ ប៉ុន្តែចាប់តាំងពីពេលនោះមក វាទាំងពីរនាក់ប្តីប្រពន្ធមិនបានទៅលស់ប្លង់ដីមកឲ្យខ្ញុំវិញនោះទេថែមទាំងរត់គេចខ្លួនបាត់ ធ្វើឲ្យយើងខ្ញុំទាំងពីរនាក់នៅជាប់ឈ្មោះជំពាក់បំណុលរបស់គេថែមទៀត។-

ខ.៤. អង្គហេតុដែលគ្មានវិវាទ៖ សហចុងចម្លើយទទួលស្គាល់ពិតជាបានផ្តិតមេដៃលើកិច្ចសន្យាខ្ចីប្រាក់ទាំងពីរលើកពិតប្រាកដមែន។

ខ.៥. ចំណុចវិវាទ៖ តើការទាមទាររបស់ដើមចោទមានលក្ខណៈត្រឹមត្រូវដែរ ឬទេ ?

## គ. ការពិនិត្យភស្តុតាង

### គ.១.ភស្តុតាងរបស់ភាគីដើមចោទ

១.ឯកសារថតចម្លង អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ០២១៣១៥៧៨៧ ចុះថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០២០ របស់ឈ្មោះ [redacted]ប៊ុនថេត។

២.ឯកសារថតចម្លង នៃអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ០២០៦២៤៧២០(០១) ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១៦ របស់ឈ្មោះ [redacted]ភាស់។

៣.ឯកសារថតចម្លង នៃអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ០២០០១៨៥៨៩(០១) ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០១៥ របស់ឈ្មោះ [redacted]សំអាត។

៤.ឯកសារថតចម្លង នៃអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ០២០៥២៥០០៤(០១) ចុះថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៥ របស់ឈ្មោះ [redacted]វុទ្ធី។

៥.ឯកសារថតចម្លង នៃកិច្ចសន្យាខ្ចីបរិភោគរវាងម្ចាស់បំណុលឈ្មោះ ហោ សុខន និងសហកូនបំណុល១.ឈ្មោះ [redacted]ប៊ុនថេត ភេទប្រុស កើតឆ្នាំ១៩៨៨ និងប្រពន្ធឈ្មោះ [redacted]ភាស់ ភេទស្រី អាយុ ៣៤ឆ្នាំ និង២.ឈ្មោះ [redacted]សំអាត ភេទស្រី កើតឆ្នាំ១៩៦៣ និងប្តីឈ្មោះ [redacted] វុទ្ធី ភេទប្រុស កើតឆ្នាំ១៩៦០ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២២។

៦.ឯកសារថតចម្លង នៃលិខិតប្រគល់ទទួលប្រាក់ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២២។

៧.ឯកសារថតចម្លង នៃវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលវត្ថុលេខ០៨១១០៦០៤-១៥២១ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០២០ ចេញដោយមន្ទីររៀបចំដែនដីនគរូបនីយកម្ម សំណង់ និងសុរិយោដី។

៨.ឯកសារថតចម្លង នៃកិច្ចសន្យាខ្ចីបរិភោគរវាងម្ចាស់បំណុលឈ្មោះ [redacted] សុខន និងសហកូនបំណុល១.ឈ្មោះ [redacted]ប៊ុនថេត ភេទប្រុស កើតឆ្នាំ១៩៨៨ និងប្រពន្ធឈ្មោះ [redacted]ភាស់ ភេទស្រី អាយុ ៣៤ឆ្នាំ និង២.ឈ្មោះ [redacted] សំអាត ភេទស្រី កើតឆ្នាំ១៩៦៣ និងប្តីឈ្មោះ [redacted] វុទ្ធី ភេទប្រុស កើតឆ្នាំ១៩៦០ ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២២។

៩.ឯកសារថតចម្លង នៃលិខិតប្រគល់ទទួលប្រាក់ ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២២។

១០.ឯកសារថតចម្លង នៃលិខិតប្រគល់ទទួលមូលប្បទានប័ត្រ ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២២។

១១.ឯកសារថតចម្លង នៃកាលវិភាគសងប្រាក់ ហាងបញ្ចាំគ្រាស់មី ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២២។

១២.ឯកសារថតចម្លង នៃមូលប្បទានប័ត្រធនាគារABA លេខ១៩០៥៥៤ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២២។

### គ.២.ភស្តុតាងរបស់ភាគីចុងចម្លើយ៖ គ្មាន



Scanned with CamScanner

## សំអាងហេតុ

យោងតាមលទ្ធផលនៃការទាញហេតុផលដោយផ្ទាល់មាត់ជាសាធារណៈ និងការពិនិត្យកស្តុតាងក្នុងសំណុំរឿងនេះរួចមកតុលាការៈ

១.យល់ឃើញថា ការទាមទារចំណុចទី០១ របស់ដើមចោទដែលសុំឲ្យតុលាការបង្គាប់ឲ្យសហចុងចម្លើយរួមគ្នាសងប្រាក់ដើមដែលនៅជំពាក់សរុបចំនួន ៦៥.០០០(ប្រាំមួយម៉ឺនប្រាំពាន់)ដុល្លារអាមេរិក មកឲ្យដើមចោទនោះ តុលាការពិនិត្យឃើញថា តាមកិច្ចសន្យាខ្ចីបរិភោគលើកទី១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២២ ដែលមានទំហំប្រាក់កម្ចីដើមចំនួន ១០០.០០០(ដប់ម៉ឺន)ដុល្លារអាមេរិក និងកិច្ចសន្យាខ្ចីបរិភោគបន្ត ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២២ ដែលមានទំហំប្រាក់កម្ចី ៥.០០០(ប្រាំពាន់) ដុល្លារអាមេរិក ដោយបានបញ្ជាក់បន្ថែមទៀតថា "ផ្អែកតាមកិច្ចសន្យាខ្ចីបរិភោគ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២២ អ្នកខ្ចីប្រាក់ត្រូវដល់កាលកំណត់សងប្រាក់ដើមចំនួន ១០០.០០០(ដប់ម៉ឺន)ដុល្លារអាមេរិក មកឲ្យម្ចាស់បំណុលវិញ នៅត្រឹមថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២២ ជាកំណត់ ក៏ប៉ុន្តែពេលដល់កាលបរិច្ឆេទកំណត់សង អ្នកខ្ចីប្រាក់បានសងប្រាក់ដើមបានតែចំនួន ៤០.០០០(បួនម៉ឺន) ដុល្លារអាមេរិក ដោយនៅជំពាក់ចំនួន ៦០.០០០(ប្រាំមួយម៉ឺន)ដុល្លារអាមេរិក និងអ្នកខ្ចីបានស្នើសុំបន្តខ្ចីបន្ថែមចំនួន ៥.០០០(ប្រាំពាន់) ដុល្លារអាមេរិក ដោយសន្យាសងផ្តាច់ទាំងប្រាក់ដើមជំពាក់មុន និងក្រោយនេះ ក្នុងអំឡុងពេល ០៥(ប្រាំ)ខែ គិតពីថ្ងៃដែលបានចុះកិច្ចសន្យានេះ" នោះឃើញថា កិច្ចសន្យាខ្ចីបរិភោគទាំងពីរលើកនេះពិតជាបានធ្វើឡើងរវាងដើមចោទឈ្មោះ [redacted]សុខន និងសហចុងចម្លើយឈ្មោះ[redacted]វុទ្ធី ,ឈ្មោះ [redacted]សំអាត ,ឈ្មោះ [redacted]ប៊ុនថេត និងឈ្មោះ [redacted]កាស់ ពិតប្រាកដមែន ហើយដែលតាមខ្លឹមសារនៃកិច្ចសន្យាទាំងពីរ ឃើញថា ដើមចោទអះអាងថា ប្រាក់ដើមដែលសហចុងចម្លើយនៅជំពាក់ខ្លួនមានចំនួន ៦៥.០០០(ប្រាំមួយម៉ឺនប្រាំពាន់)ដុល្លារអាមេរិក រួមទាំងការប្រាក់ និងប្រាក់ពិន័យថែមទៀតផង។ ចំពោះការអះអាងរបស់ដើមចោទនេះ សហចុងចម្លើយឈ្មោះ [redacted]វុទ្ធី និងឈ្មោះ [redacted] សំអាត បានបដិសេធដោយធ្វើវិភាគកម្មថា ពួកខ្លួនទទួលស្គាល់ថា ពិតជាបានផ្តិតស្នាមម្រាមដៃលើកិច្ចសន្យាខ្ចីបរិភោគនោះពិតមែន ប៉ុន្តែពួកខ្លួនពុំដែលទទួលបានប្រាក់កម្ចីនោះម្តងណាឡើយ គឺកូនរបស់ពួកខ្លួនជាអ្នកទទួលទាំងអស់។ ត្រង់ចំណុចនេះ តុលាការយល់ឃើញថា សហចុងចម្លើយទាំង ៤នាក់ គឺជាឪពុកម្តាយ និងកូនពោលគឺ ជាញាតិក្នុងវង្វង់គ្រួសារតែមួយ ហើយបានទៅខ្ចីប្រាក់រួមគ្នាពីដើមចោទឈ្មោះ [redacted]សុខន តាមរយៈកិច្ចសន្យាចំនួនពីរលើក ដែលតុលាការពិនិត្យឃើញថា ប្រាក់ដែលនៅជំពាក់មានចំនួន ៦៥.០០០(ប្រាំមួយម៉ឺនប្រាំពាន់)ដុល្លារអាមេរិក ហើយសហចុងចម្លើយឈ្មោះ[redacted]ប៊ុនថេត និងឈ្មោះ [redacted]កាស់ ជាអ្នកទទួលប្រាក់ពីដើមចោទ ហេតុនេះ ការចោត់ចែងប្រាក់កម្ចីដែលបានមកនោះដោយរបៀបណា រវាងសហចុងចម្លើយទាំង ៤នាក់គឺ ស្ថិតក្នុងវង្វង់ផ្ទៃក្នុងគ្រួសារដែលឃើញថាអត្ថិភាព នៃអង្គហេតុនៃការខ្ចីប្រាក់ និងអង្គហេតុទទួលប្រាក់គឺ មានគ្រប់គ្រាន់ដែលសហចុងចម្លើយទាំង ៤រូបត្រូវមានកាតព្វកិច្ចដោយសាមគ្គីក្នុងការសងទៅដើមចោទវិញ ហេតុនេះ គប្បីតុលាការទទួលស្គាល់ការទាមទារចំណុចទី១ដើមចោទ និងបង្គាប់ឲ្យសហចុងចម្លើយទាំងអស់រួមគ្នាសងប្រាក់ដើមដែលនៅជំពាក់ចំនួន ៦៥.០០០(ប្រាំមួយម៉ឺនប្រាំពាន់) ដុល្លារអាមេរិក ឲ្យទៅដើមចោទវិញ។

២.ចំពោះការទាមទារចំណុចទី២ របស់ដើមចោទរបស់ដើមចោទដែលសុំឲ្យតុលាការបង្គាប់ឲ្យសហចុងចម្លើយរួមគ្នាសងប្រាក់ក្នុងអាត្រា ១.៥%នៃប្រាក់ដើមដែលនៅជំពាក់គិតចាប់ពីថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២២ រហូតដល់ពេលសងគ្រប់ចំនួននោះ តុលាការពិនិត្យឃើញថា តាមកិច្ចសន្យាខ្ចីបរិភោគចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២២ រវាងដើមចោទ និងចុងចម្លើយត្រង់ប្រការ១.៣ បានកំណត់យកការប្រាក់ចំនួន ២% ក្នុងមួយខែដែលចំនួននេះ ត្បិតតែជាការព្រមព្រៀងគ្នារវាងគូភាគី ប៉ុន្តែគឺលើសពីអត្រាការប្រាក់ដែលច្បាប់កម្រិតហើយ ហេតុនេះយោងតាម



Scanned with CamScanner

ប្រកាសរបស់ក្រសួងយុត្តិធម៌លេខ ១២៨កយ.ប្រក/១១ ស្តីពីអត្រាការប្រាក់ដែលត្រូវបានកម្រិត គប្បីតុលាការទទួលស្គាល់ និងសម្រេចបង្គាប់ឲ្យសហចុងចម្លើយរួមគ្នាសងការប្រាក់ក្នុងអត្រា ១.៥% ក្នុងមួយខែ នៃប្រាក់ដើមដែលនៅជំពាក់ទៅឲ្យដើមចោទវិញ ដោយហេតុថា សហចុងចម្លើយនៅតែបន្តប្រើប្រាស់ប្រាក់ដើមនេះនៅឡើយ។

៣.ចំពោះការទាមទារចំណុចទី៣ របស់ដើមចោទដែលសុំឲ្យតុលាការបង្គាប់ឲ្យសហចុងចម្លើយរួមគ្នាសងប្រាក់ពិន័យក្នុងអត្រា ៥% ក្នុងមួយខែ ឲ្យទៅដើមចោទគិតចាប់ពីថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២២ រហូតដល់សងគ្រប់ចំនួន តុលាការពិនិត្យឃើញថា នេះគឺជាការកំណត់ទុកជាមុននូវសំណងការខូចខាតរវាងភាគីនៃកិច្ចសន្យា ហើយយោងតាមកិច្ចសន្យាខ្ចីបរិភោគចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២២ ត្រង់ប្រការ១.៦ ឃើញថា គូភាគីពិតជាបានព្រមព្រៀងគ្នាកំណត់អត្រា ៥% ក្នុងមួយខែ លើប្រាក់ដើមដែលនៅជំពាក់ ជាការប្រាក់ពិន័យយឺតយ៉ាវពិតប្រាកដមែន ក៏ប៉ុន្តែការប្រាក់ពិន័យនេះគឺ លើសពីការកម្រិតរបស់ច្បាប់ហើយ ហើយដោយយោងតាមប្រកាសរបស់ក្រសួងយុត្តិធម៌ដូចក្នុងសំអាងហេតុទី២ ខាងលើដែល គប្បីតុលាការទទួលស្គាល់ និងសម្រេចបង្គាប់ឲ្យសហចុងចម្លើយរួមគ្នាសងការប្រាក់ពិន័យក្នុងអត្រាការប្រាក់ ២.២៥% ក្នុងមួយខែ នៃប្រាក់ដើមដែលនៅជំពាក់គិតចាប់ពីថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២២ រហូតដល់សងប្រាក់គ្រប់ចំនួនទៅឲ្យដើមចោទតែប៉ុណ្ណោះ ហើយការទាមទារលើសពីនេះ គប្បីច្រានចោល។

៤.ចំពោះការទាមទារចំណុចទី៤ របស់ដើមចោទដែលទាមទារសំណងជម្ងឺចិត្ត និងការខាតបង់ពេលវេលាក្នុងចំនួន ២០.០០០(ពីរម៉ឺន)ដុល្លារអាមេរិក ពីចុងចម្លើយនោះ តុលាការពិនិត្យឃើញថា ដើមចោទពុំបានដាក់បញ្ចូលនូវភស្តុតាងស្តីពីការខូចខាតជាក់លាក់ណាមួយមកឲ្យតុលាការពិនិត្យនោះទេ ម្យ៉ាងវិញទៀតដោយដើមចោទនឹងទទួលបានសំណងការខូចខាតពីអត្រាការប្រាក់ពិន័យដូចក្នុងសំអាងហេតុចំណុចទី៣ ខាងលើហើយនោះ គប្បីតុលាការច្រានចោលការទាមទារត្រង់ចំណុចនេះរបស់ដើមចោទ។

៥.ចំពោះការទាមទារចំណុចទី៥ របស់ដើមចោទ ដែលសុំប្រកាសអនុវត្តបណ្តោះអាសន្ន ចំពោះសាលក្រមនេះ តុលាការយល់ឃើញថា មានភាពចាំបាច់ពិសេសចំពោះតែទៅលើប្រាក់ដើមប៉ុណ្ណោះ ដែលគប្បីប្រកាសអនុវត្តបណ្តោះអាសន្ន ដោយឡែកចំពោះការសម្រេចលើការទាមទារផ្សេងទៀត មិនគប្បីប្រកាសអនុវត្តបណ្តោះអាសន្ននោះទេ។

៦.យោងតាមមាត្រា៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណីប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ភាគីចាញ់ក្តី។

**សេចក្តីសម្រេចបញ្ចប់**

១.បង្គាប់ឲ្យសហចុងចម្លើយឈ្មោះ [redacted] វុទ្ធី, ឈ្មោះ [redacted] សំអាត, ឈ្មោះ [redacted] ប៊ុនថេត និងឈ្មោះ [redacted] ភាស់ រួមគ្នាសងប្រាក់ដើមសរុបចំនួន ៦៥.០០០(ប្រាំមួយម៉ឺនប្រាំពាន់)ដុល្លារអាមេរិក ទៅឲ្យដើមចោទឈ្មោះ [redacted] សុខន។

២.បង្គាប់ឲ្យសហចុងចម្លើយចម្លើយឈ្មោះ [redacted] វុទ្ធី, ឈ្មោះ [redacted] សំអាត, ឈ្មោះ [redacted] ប៊ុនថេត និងឈ្មោះ [redacted] ភាស់ រួមគ្នាសងការប្រាក់ក្នុងអត្រា ១.៥%(មួយក្បៀសប្រាំភាគរយ) ក្នុងមួយខែ លើប្រាក់ដើមចំនួន ៦៥.០០០ (ប្រាំមួយម៉ឺនប្រាំពាន់)ដុល្លារអាមេរិក ដោយគិតចាប់ពីថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២២ រហូតដល់ថ្ងៃសងរួចទៅឲ្យដើមចោទឈ្មោះ [redacted] សុខន។

៣.បង្គាប់ឲ្យសហចុងចម្លើយចម្លើយឈ្មោះ [redacted] វុទ្ធី, ឈ្មោះ [redacted] សំអាត, ឈ្មោះ [redacted] ប៊ុនថេត និងឈ្មោះ [redacted] ភាស់ រួមគ្នាសងការប្រាក់យឺតយ៉ាវក្នុងអត្រា ២.២៥%(ពីរក្បៀសម្ភៃប្រាំភាគរយ) ក្នុងមួយខែ ដោយគិតចាប់ពីថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២២ រហូតដល់ថ្ងៃសងរួចទៅឲ្យដើមចោទឈ្មោះ [redacted] សុខន។

៤.ច្រានចោលការទាមទារសំណងជម្ងឺចិត្ត ការខូចខាតបង់ប្រាក់ពេលវេលា និងប្រាក់កម្រៃសេវាមេធាវីចំនួន ២០.០០០(ពីរម៉ឺន)ដុល្លារអាមេរិក។



Scanned with CamScanner

៥.ប្រកាសអនុវត្តបណ្ដោះអាសន្ន ត្រង់ចំណុចទី១ នៃសេចក្ដីសម្រេចបញ្ចប់ខាងលើ។

៦.ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់សហចុងចម្លើយ។

សាលក្រមនេះ បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់នៅថ្ងៃទី១០ ខែមេសា ឆ្នាំ២០២៤ និងប្រកាសជាសាធារណៈនៅថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០២៤ ចំពោះមុខដើមចោទឈ្មោះ [redacted]សុខន និងសហចុងចម្លើយឈ្មោះ [redacted] វុទ្ធី និងឈ្មោះ [redacted]សំអាត និងកំបាំងមុខសហចុងចម្លើយឈ្មោះ[redacted]ុនថេត និងឈ្មោះ [redacted]កាស់។

*ភាគីមានសិទ្ធិប្ដឹងទាស់ ឬប្ដឹងឧទ្ធរណ៍នឹងសាលក្រមនេះតាមការកំណត់របស់ច្បាប់ ។*

**ចៅក្រម**

ហត្ថលេខា និងត្រា [redacted]

---

"បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម"

ថ្ងៃអង្គារ ១៣រោច ខែចេត្រ ឆ្នាំរោង ឆស័ក ព.ស២៥៦៨

កណ្ដាល, ថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០២៤

បានឃើញ

**ចៅក្រមជំនុំជម្រះ**

[redacted]

**ក្រឡាបញ្ជី**

[redacted]